# សេចក្តីប្រកាសព័ត៌មាន

## រាជរដ្ឋាភិបាលកម្ពុជា និងដៃគូ សហការការពារកិច្ចអប់រំរបស់កុមារតូច ដោយផ្តល់នូវកញ្ចប់សម្ភារអប់រំតាមផ្ទះចំនួន ៧៥០.០០០ កញ្ចប់

**រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០២១៖** ថ្ងៃនេះក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីដៃគូនៃមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាព (CDPF) សហភាពអឺរ៉ុប (EU) មូលនិធិសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ស៊ុយអែត (SIDA) និងភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) បានប្រកាសជាផ្លូវការអំពីការចែកចាយសម្ភារសិក្សាតាមផ្ទះចំនួន ៧៦០.១៨០ កញ្ចប់ ជាការឧបត្ថម្ភដល់កុមារតូចៗដែលរងផលប៉ះពាល់ដោយសារការអាក់ខានរៀនសូត្រនៅតាមសាលារៀននានានៅកម្ពុជា។ ការចែកសម្ភារដែលនឹងចាប់ផ្តើមនៅសប្តាហ៍នេះ នឹងបានទៅដល់ដៃកុមារគ្រប់រូប ដែលសិក្សានៅថ្នាក់ទី ១ និងទី ២ នៃសាលាបឋមសិក្សារដ្ឋទាំង ៧.៣០៤ កន្លែងនៅទូទាំង ២៥ រាជធានី និងខេត្ត ។ លើសពីនេះ ក៏មានការរៀបចំឯកសារបន្ថែមទៀត សម្រាប់គាំទ្រសិស្សានុសិស្សនិយាយភាសាដើមភាគតិចចំនួន ៥.០០០ នាក់ នៅខេត្តភាគឦសាននៃប្រទេសកម្ពុជា ដើម្បីជួយឱ្យពួកគេសិក្សាដោយប្រើប្រាស់ភាសាផ្ទាល់ខ្លួនបានផងដែរ។

ខណៈដែលសាលារៀនជាច្រើនបានចាប់ផ្តើមបើកដំណើរការឡើងវិញ សាលារៀនភាគច្រើនកំពុងប្រើប្រាស់វិធីសាស្ត្រសិក្សាបែបចម្រុះ ដោយបញ្ចូលការសិក្សាផ្ទាល់ជាមួយនឹងការសិក្សាតាមផ្ទះ។ កញ្ចប់សម្ភារសិក្សាតាមផ្ទះថ្មីទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីគាំទ្រកុមាររៀនផ្ទាល់ក្នុងថ្នាក់រៀនផង និងនៅឯផ្ទះផង ដោយឯកសារទាំងនេះត្រូវបានសម្រិតសម្រាំងឱ្យងាយសិក្សា និងមានប្រសិទ្ធភាពនៅគ្រប់ស្ថានភាពទាំងអស់។ សម្រាប់កុមារដែលសាលារៀនរបស់ពួកគេនៅតែបន្តបិទទ្វារដោយសារតែកត្តាហានិភ័យនានាបង្កដោយជំងឺកូវីដ-១៩ កញ្ចប់សម្ភារអប់រំទាំងនេះគឺជាធនធានដ៏មានតម្លៃដើម្បីធានាថាកុមារទាំងនោះនៅតែអាចបន្តការសិក្សារបស់ខ្លួនបាន។

កញ្ចប់សម្ភារអប់រំទាំងនេះរួមមាន សៀវភៅពុម្ពសំរាប់កុមារតាមវ័យ និងឯកសារស្វ័យសិក្សា ដើម្បីពង្រឹងអំណាន សំណេរ ការប្រកប និងគណិតវិទ្យា ដែលសុទ្ធតែជួយបំពេញបន្ថែមលើកម្មវិធីសិក្សា ថ្នាក់ទី ១ និងថ្នាក់ទី ២ របស់ក្រសួងអប់រំ យុវជន និងកីឡា។ កញ្ចប់សម្ភារទាំងនេះក៏មានបញ្ចូលព័ត៌មានអំពីវិធីសាស្ត្រដែលមាតាបិតាអាចប្រើប្រាស់ដើម្បីជួយគាំទ្រដល់ការអប់រំកូនៗ និងបន្តការពារពួកគេពីជំងឺកូវីដ-

១៩ ដោយមានបញ្ចូលសាប៊ូមួយដុំ និងវេចខ្ចប់ដាក់ក្នុងកាបូបមេត្រីបរិស្ថាន សម្រាប់យកមកប្រើប្រាស់ឡើងវិញបានផងដែរ។

ការចែកចាយកញ្ចប់សម្ភារសិក្សាតាមផ្ទះ ត្រូវបានប្រកាសក្នុងពិធីមួយដែលរៀបចំឡើងនៅទីក្រុងភ្នំពេញកាលពីព្រឹកមិញនេះតាមរយៈប្រព័ន្ធវីដេអូខនហ្វើរិនស៍។ វាគ្មិនកិត្តិយសដែលចូលរួមក្នុងពិធីនេះរួមមាន ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកស្រី Carmen Moreno ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា លោក Magnus Saemundsson លេខាទី ១ នៃស្ថានទូតស៊ុយអែត លោកស្រី Hanh Nguyen ប្រធានបេសកកម្មស្តីទីរបស់ USAID កម្ពុជា និងលោកស្រី Foroogh Foyouzat តំណាងយូនីសេហ្វនៅកម្ពុជា។

ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ថា៖ "នេះគឺជាពេលវេលាដ៏សែនលំបាកសម្រាប់ការអប់រំនៅទូទាំងពិភពលោករួមទាំងនៅកម្ពុជាផងដែរ។ យើងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការគាំទ្រដែលផ្តល់ដោយដៃគូដ៏មានតម្លៃរបស់យើង ដូចជា សហភាពអឺរ៉ុប SIDA, USAID, GPE និងយូនីសេហ្វ ក្រោមមូលនិធិភាពជាដៃគូដើម្បីអភិវឌ្ឍន៍សមត្ថភាព (CDPF) ដើម្បីជួយកម្ពុជាក្នុងការគាំទ្រសិស្សានុសិស្សក្នុងអំឡុងនៃការរាតត្បាតជំងឺកូវីដ-១៩ជាសកលនេះ។ បច្ចុប្បន្ននេះយើងកំពុងចាប់ផ្តើមបើកដំណើរការសាលារៀនឡើងវិញ ប៉ុន្តែយើងត្រូវតែធ្វើការងារនេះយ៉ាងប្រុងប្រយ័ត្នដោយប្រើប្រាស់យុទ្ធសាស្ត្របញ្ចូលគ្នារវាងការសិក្សាផ្ទាល់ក្នុងសាលារៀន ជាមួយនឹងការសិក្សានៅតាមផ្ទះ។ សម្ភារសិក្សាទាំងនេះនឹងជួយយើងឲ្យយុទ្ធសាស្ត្រថ្មីនេះទទួលបានជោគជ័យ និងជាពិសេសសម្រាប់ជាជំនួយដល់សិស្សចំនួន ៥០% ដែលពុំមានលទ្ធភាពរៀនសូត្រតាមប្រព័ន្ធអនឡាញនៅតាមផ្ទះរបស់ពួកគេបាន។ សូមថ្លែងអរគុណដល់ការឧបត្ថម្ភនេះ សិស្សានុសិស្សថ្នាក់ទី ១ និងទី ២ របស់យើងនឹងបានសិក្សាត្រៀម និងអាចចាប់ផ្តើមបានយ៉ាងល្អនៅពេលដែលថ្នាក់រៀនបើកដំណើរការពេញលេញឡើងវិញ។"

លោកស្រី Carmen Moreno ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា៖ "សាលារៀននឹងបើកដំណើរការឡើងវិញ ប៉ុន្តែសិស្សទាំងនេះមិនអាចត្រឡប់ទៅអាយុ ៦ ឬ ៧ ឆ្នាំម្តងទៀតបានឡើយ អាយុកម្រិតនេះផ្តល់ឱកាសល្អបំផុតសម្រាប់ឱ្យកុមាររៀនអាន ប្រកបអក្សរ និងរាប់លេខបានយ៉ាងល្អ។ យើងមិនអាចមិនអើពើ និងទុកកុមារទាំងនេះឲ្យបន្តខកខានការសិក្សារបស់ពួកគេឡើយ។ ពួកគេមានសិទ្ធិទទួលបានការអប់រំ ទោះជាស្ថិតនៅក្នុងបរិបទដ៏សែនលំបាកនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ក៏ដោយ។ យើងដឹងថាការសិក្សាដោយប្រើឯកសារជាក្រដាសសម្រាប់កុមារនៅក្រុមអាយុនេះ មានប្រសិទ្ធភាពជាងការសិក្សាតាមប្រព័ន្ធអនឡាញ។ ដូចនេះហើយទើបយើងរីករាយជាខ្លាំងក្នុងការ

សហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូ CDPF ទាំងអស់របស់យើង ដើម្បីផ្តល់នូវកញ្ចប់សម្ភារៈសម្រាប់សិក្សានៅតាមផ្ទះទាំងនេះ។ ការចែកសម្ភារសិក្សាដល់សិស្សថ្នាក់ទី ១ និងទី ២ គ្រប់រូបនៅកម្ពុជា បង្ហាញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងសាមគ្គីភាពរបស់សហភាពអឺរ៉ុប និងរដ្ឋជាសមាជិកនៃសហភាពអឺរ៉ុប ដែលហៅថា ក្រុមអឺរ៉ុប (Team Europe) ដើម្បីប្រយុទ្ធប្រឆាំងផលប៉ះពាល់ដែលបង្កឡើងដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។

លោកស្រី Carmen Moreno បានបន្ថែមទៀតថា៖ "រដ្ឋាភិបាល និងដៃគូនានា ដូចជាយូនីសេហ្វជាដើម បានខិតខំប្រឹងប្រែង ដើម្បីជួយដល់សិស្សានុសិស្សទូទាំងប្រទេសកម្ពុជា តាមរយៈការផ្តល់ឱ្យពួកគេនូវធនធានរៀនពីចម្ងាយ ចាប់តាំងពីថ្នាក់រៀនរបស់ពួកគេបិទទ្វារជាលើកទី ១ មកម្ល៉េះ។ ទោះជាយ៉ាងនេះក្តី យើងដឹងថាការរៀនតាមអនឡាញពុំមានប្រសិទ្ធភាពដូចការរៀននៅក្នុងថ្នាក់ផ្ទាល់ ឬការរៀនដោយប្រើប្រាស់ឯកសារជាគោលនោះឡើយ។ ដូច្នេះយើងមានមោទកភាពដែលបានសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើតឯកសារសម្រាប់សិក្សាតាមផ្ទះនេះ ដើម្បីបំពេញបន្ថែមលើកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា និងចែកឯកសារទាំងនេះដល់សិស្សថ្នាក់ទី ១ និងទី ២ គ្រប់រូបនៅគ្រប់ភូមិទាំងអស់ក្នុងប្រទេសកម្ពុជា។ ខណៈដែលសាលារៀនចាប់ផ្តើមបើកដំណើរការឡើងវិញ គោលបំណងនៃការចែកចាយកញ្ចប់សម្ភារសិក្សាទាំងនេះ គឺដើម្បីធានាថាគ្មានកុមារណាម្នាក់ត្រូវបានទុកចោលមិនឲ្យរៀនសូត្រនោះឡើយ។

លោក Magnus Saemundsson លេខាទី ១ នៃស្ថានទូតស៊ុយអែត មានប្រសាសន៍ថា៖ "ភស្តុតាងដែលរកឃើញតាមរយៈការស្រាវជ្រាវជុំវិញពិភពលោកបង្ហាញថា ការអប់រំនាំមកនូវការផ្លាស់ប្តូរយូរអង្វែងសម្រាប់ជីវិតរបស់កុមារ។ ការអប់រំមិនត្រឹមតែប្រសើរសម្រាប់បុគ្គលម្នាក់ៗប៉ុណ្ណោះទេ ការអប់រំគឺប្រសើរសម្រាប់ប្រជាជាតិទាំងមូលទៀតផង។ ការវិនិយោគលើការអប់រំមិនត្រឹមតែជារឿងត្រឹមត្រូវដែលត្រូវធ្វើប៉ុណ្ណោះទេ តែជាការវិនិយោគសេដ្ឋកិច្ចដ៏វៃឆ្លាត។ ភស្តុតាងនានាបង្ហាញថា ជាមធ្យមការទទួលបានការអប់រំបន្ថែម ១ ឆ្នាំ ជួយឱ្យបុគ្គលម្នាក់កើនចំណូលបាន ១០% និងបង្កើន ផ.ស.ស. របស់ប្រទេសបាន ១៨%។ ការបិទសាលាទាំងអស់នៅកម្ពុជាដើម្បីការពារការឆ្លងរាលដាលវីរុសរាតត្បាតជាសកល បានបង្កការខាតបង់ដល់វិស័យអប់រំយ៉ាងមហិមា ហើយមិនខុសគ្នាទេបញ្ហានេះកំពុងតែកើតឡើងក្នុងប្រទេសជាច្រើននៅក្នុងពិភពលោកផងដែរ។ បច្ចុប្បន្ននេះ ខណៈដែលសាលារៀនកំពុងបើកដំណើរការឡើងវិញដោយអនុវត្តវិធានការសុវត្ថិភាពជាគោល ជាការសំខាន់ណាស់ដែលត្រូវមានការរៀបចំយ៉ាងណាឱ្យការប្រើប្រាស់យុទ្ធសាស្ត្របញ្ចូលគ្នាពោលគឺការសិក្សាក្នុងថ្នាក់ផង និងការសិក្សាតាមផ្ទះផងទទួលបានជោគជ័

យ។ កញ្ចប់សម្ភារសិក្សាតាមផ្ទះនេះ នឹងមានប្រយោជន៍បំផុត ដើម្បីជួយឱ្យយើងសម្រេចគោលដៅខាងលើនេះបានដោយជោគជ័យ។"

លោកស្រី Hanh Nguyen ប្រធានបេសកកម្មស្តីទីរបស់ USAID កម្ពុជាមានប្រសាសន៍ថា៖ "USAID គឺជាអ្នកគាំទ្រប្រកបដោយមោទកភាពជាយូរមកហើយសម្រាប់ពលរដ្ឋកម្ពុជា។ ការសហការរបស់យើងជាមួយនឹងដៃគូចម្រុះដែលកំពុងមានវត្តមាននៅទីនេះ រាប់បញ្ចូលទាំងគ្រូ និងសិស្សានុសិស្សដែលជាអ្នកពោរពេញដោយការប្តេជ្ញាចិត្តនៅកម្ពុជា គឺជាសក្ខីកម្មដែលបង្ហាញពីការគាំទ្រនេះ។ USAID ជឿថាក្រុមការងារដែលពោរពេញដោយការប្តេជ្ញាចិត្ត ហើយដែលបានខិតខំចែករំលែកជំនាញ និងបទពិសោធបច្ចេកទេសរបស់ខ្លួនអាចនាំឱ្យមានលទ្ធផលជាក់លាក់ និងប្រសិទ្ធភាពយូរអង្វែង។ កញ្ចប់សម្ភារសិក្សាដែលកំពុងត្រូវបានចែកចាយនៅថ្ងៃនេះ ត្រូវបានរៀបចំឡើងដោយអ្នកអប់រំនៅកម្ពុជា អ្នកជំនាញរបស់ក្រសួង អ្នកនិពន្ធជាតិ និងអ្នករចនាក្រាហ្វិក។ សម្ភារទាំងនេះគឺជាធនធានដ៏មានតម្លៃសម្រាប់បម្រើ ផលប្រយោជន៍សាលារៀន និងសហគមន៍ មិនត្រឹមតែក្នុងអំឡុងដែលមានការរំខានដោយសារជំងឺកូវីដ-១៩ ប៉ុណ្ណោះទេ ថែមទាំងសម្រាប់ប្រើប្រាស់ដល់ជំនាន់ក្រោយៗទៀតផង។"

## សាវតារ

មូលនិធិភាពជាដៃគូដើម្បីអភិវឌ្ឍន៍សមត្ថភាព (CDPF) គឺជាភាពជាដៃគូរវាងក្រសួងអប់រំ យុវជន និងកីឡា សហភាពអឺរ៉ុប (EU) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត (SIDA) ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) និងយូនីសេហ្វ។ តាមរយៈយន្តការមូលនិធិបញ្ចូលគ្នា CDPF ផ្តល់ការគាំទ្រដល់ការអនុវត្តអាទិភាពជុំវិញ ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ។ CDPF បានចូលមកដល់ដំណាក់កាលទី ៣ កាលពីឆ្នាំ ២០១៨ ដែលនឹងបន្តរហូតដល់ខែមិថុនា ឆ្នាំ ២០២៣ ដើម្បីជួយគាំទ្រដល់គំនិតផ្តួចផ្តើមកសាងសមត្ថភាពក្នុងទឹកប្រាក់ប្រមាណ ៣២ លានដុល្លារ។ ដំណាក់កាលថ្មីនេះត្រូវបានរៀបចំឡើងផ្អែកតាមជោគជ័យ ដែលទទួលបានពីដំណាក់កាល ២ មុនៗដែលអនុវត្តចាប់តាំងពីឆ្នាំ ២០១១ ជាមួយនឹងថវិកាបន្ថែមសរុបចំនួន ២៤ លានដុល្លារ។

CDPF បានបន្តផ្តល់ការគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងអំឡុងដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដូចជា តាមរយៈការចែកសម្ភារអនាម័យ កាលពីឆ្នាំ ២០២០ ដល់សាលារៀនទាំងអស់ ប្រាស្រ័យទាក់ទងដោយប្រើប្រាស់វិធីសាស្ត្រសមស្រប ការរៀបចំឯកសារ សម្ភារសម្រាប់គាំទ្រដល់ការបន្តសិក្សរៀនសូត្ររបស់កុមារ និងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សមត្ថភាពផ្សេងទៀត។

## អំពីសហភាពអឺរ៉ុប (EU)

សហភាពអឺរ៉ុប (EU) គឺជាសហភាពសេដ្ឋកិច្ច និងនយោបាយដ៏ពិសេស ដែលមានសមាជិកចំនួន ២៧ ប្រទេស ដែលរួមគ្នាគ្របដណ្ដប់លើផ្ទៃដីភាគច្រើននៃទ្វីបនេះ។ សហភាពអឺរ៉ុប គឺជាដៃគូពាណិជ្ជកម្មធំជាងគេទី ២ របស់កម្ពុជា និងជាដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ធំជាងគេមួយរបស់ប្រទេសនេះ បើគិតបញ្ចូលជាមួយនឹងរដ្ឋជាសមាជិកនៃសហភាពអឺរ៉ុប។

សហភាពអឺរ៉ុប គឺជាស្ថាប័នរួមចំណែកធំជាងគេដល់វិស័យអប់រំនៅកម្ពុជា។ សហភាពអឺរ៉ុប និងរដ្ឋជាសមាជិករួមគ្នាវិនិយោគលើកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់វិស័យអប់រំច្រើនជាងប្រទេសដទៃទៀតនៅក្នុងពិភពលោក។

សូមតាមដានព័ត៌មានអំពីប្រតិភូសហភាពអឺរ៉ុបនៅកម្ពុជាតាមរយៈ ហ្វេសប៊ុក។

ព័ត៌មានទំនាក់ទំនង

**ឯកឧត្តមបណ្ឌិត រស់ សុខវាចា** អ្នកនាំពាក្យក្រសួងអប់រំយុវជន និងកីឡា ទូរស័ព្ទ៖ +855 78 755 556 ឬ អ៊ីមែល៖ soveacha2002@yahoo.com

**ពូន ប៉ុក** មន្ត្រីសារព័ត៌មាន និងព័ត៌មាន ប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ (+855) 12 347 716 ឬអ៊ីមែល៖ pok.poun@eeas.europa.eu